# សេចក្តីថ្លែងការណ៍របស់ដៃគូអភិវឌ្ឍន៍

## របៀបវារៈទី IIIB : កំណែទម្រង់រដ្ឋបាលសាធារណៈ

**ថ្លែងដោយឯកឧត្តម** Frank Marcus Mann **ឯកអគ្គរាជទូតនៃប្រទេសអាល្លឺម៉ង់ប្រចាំនៅកម្ពុជា**

**តំណាងដៃគូអភិវឌ្ឍន៍ នៅក្នុងវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទីបី**

**រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែមិថុនា ឆ្នាំ២០១០**

សូមគោរព ឯកឧត្តម **គាត ឈន់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
សូមគោរព ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ជាទីគោរពរាប់អាន!

ក្នុងនាមដៃគូអភិវឌ្ឍន៍ទាំងអស់ចំពោះរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំងដែលមានឱកាស ក្នុងការធ្វើបទអន្តរគមន៍អំពីកំណែទម្រង់រដ្ឋបាលសាធារណៈ ។

នៅក្នុងរាជរដ្ឋាភិបាលកម្ពុជា និងរវាងរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ទាំងអស់បានចាត់ទុកថា កំណែទម្រង់រដ្ឋបាលសាធារណៈ គឺជាប្រធានបទមួយដែលបាននឹងកំពុងធ្វើការពិភាក្សាយ៉ាងច្រើន ជាពិសេសក្នុងរយៈពេលប៉ុន្មានខែកន្លងមកនេះ ។ ដូច្នេះ ជាបឋម ខ្ញុំសូមធ្វើការកោតសរសើរដោយស្មោះចំពោះការដឹកនាំរបស់ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលសាធារណៈ និងកិច្ចខិតខំប្រឹងប្រែងក្នុងការបំពេញការងារយ៉ាងសកម្មរបស់មន្ត្រីរាជការទាំងអស់ ព្រមទាំងដៃគូអភិវឌ្ឍន៍នានា ដែលស្ថិតនៅក្នុងក្រុមការងារបច្ចេកទេសកំណែទម្រង់រដ្ឋបាលសាធារណៈ ។ ជាលទ្ធផលនៃការងារនេះ យើងខ្ញុំជាដៃគូអភិវឌ្ឍន៍ទាំងអស់ មានសេចក្តីរាយក្នុងការផ្តល់អនុលោមភាពថ្ងៃនេះលើសំណើសូចនាករតាមដានត្រួតពិនិត្យរួមគ្នា ដែលពាក់ព័ន្ធនឹងកំណែទម្រង់រដ្ឋបាលសាធារណៈ និងសង្កត់ទៅលើការប្តេជ្ញាចិត្ត ដើម្បីគាំទ្ររាជរដ្ឋាភិបាល ហើយយើងនឹងបន្តធ្វើការជាមួយគ្នា ដើម្បីពង្រឹងនូវភាពខ្លាំង ការឆ្លើយតប វិជ្ជាជីវៈ ប្រសិទ្ធភាព និងតម្លាភាពនៃការងាររដ្ឋបាល ។

គួរកត់សម្គាល់ថា ការងារកំណែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល គឺជាផ្នែកមួយដ៏សំខាន់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ហើយសម្រាប់ខ្លួនខ្ញុំផ្ទាល់ក៏មានការឯកភាពទាំងស្រុងលើចំណុចនេះ ។ ដូចរាជរដ្ឋាភិបាលកម្ពុជាបានកំណត់នូវគោលដៅរួមមួយ គឺ "**បំរើប្រជាជនឱ្យបានកាន់តែល្អប្រសើរ**" ហើយមានបំណងក្នុងការសម្រេចបាននូវគោលដៅនេះ តាមរយៈការរៀបចំសេវាសាធារណៈឱ្យកាន់តែមានតម្លាភាព កាន់តែមានប្រសិទ្ធិភាព និង

មានការឆ្លើយតប ដែលនេះគឺជាចក្ខុវិស័យមួយដ៏ធំធេង។ ជាក់ស្តែង បើយើងនិយាយអំពីការកាត់បន្ថយ អត្រាមរណៈរបស់មាតា ការគ្រប់គ្រងជីផ្លឺ សំណាញ់ការពារសុវត្ថិភាពសង្គម ការបង្កើតឱ្យមានល័ក្ខខ័ណ្ឌសមស្រប សម្រាប់ការងារកសិកម្ម ដែលភាគច្រើននៃបញ្ហាទាំងនេះ យើងនឹងធ្វើការពិភាក្សានៅក្នុងថ្ងៃនេះ និងថ្ងៃស្អែកនឹងអាចមានការរីកចំរើនទៅបានប្រកប ដោយចិរភាព និងមានភាពជាក់ស្តែង លុះត្រាតែគុណភាពនៃរដ្ឋបាលសាធារណៈត្រូវបានលើកកម្ពស់។

យើងខ្ញុំជាដៃគូអភិវឌ្ឍន៍ទាំងអស់ មានការគាំទ្រយ៉ាងពេញទំហឹង ជាពិសេសចំពោះកិច្ចខិតខំប្រឹងប្រែងទាំងឡាយដើម្បីលើកកម្ពស់ការអនុវត្តការងារ និងគណនេយ្យភាព តាមរយៈការធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងបុគ្គលិក។ នៅក្នុងបរិបទនៃការងារកំណែទម្រង់រដ្ឋបាលសាធារណៈថ្នាក់ជាតិ ការពិនិត្យមើលឡើងវិញនូវយន្តការគណនេយ្យភាព និងការលើកទឹកចិត្តរួម ទាំងកំណែទម្រង់ក្នុងការទូទាត់សងដល់បុគ្គលិក គឺជាការងារដែលមានសារៈសំខាន់បំផុត។ ពាក់ព័ន្ធនឹងបញ្ហានេះ បច្ចុប្បន្ន មានការផ្តួចផ្តើមមួយចំនួនក្នុងការរៀបចំលើការងារនេះ ដូចជា ការធ្វើជំរឿនមន្ត្រីរាជការ ឬការបង្កើតឱ្យមាននូវទីភ្នាក់ងារប្រតិបត្តិការពិសេសនានា ដែលកំពុងអនុវត្តនៅក្នុងវិស័យសុខាភិបាល។ រាជរដ្ឋាភិបាល ដូចបានពន្យល់នៅក្នុងសូចនាករតាមដានត្រួតពិនិត្យរួមគ្នា ក៏មានការប្តេជ្ញាចិត្តចំពោះការផ្តួចផ្តើមផ្សេងទៀតផងដែរ ដោយរួមទាំងការរៀបចំបញ្ចប់នូវកំណែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល ការពិនិត្យមើលឡើងវិញលើផ្នែកប្រតិបត្តិការ និងការពង្រឹងដំណើរការនៃការគ្រប់គ្រងធនធានមនុស្ស។

**ឯកឧត្តម លោកជំទាវ លោក លោកស្រីជាទីគោរព!**

យើងខ្ញុំសូមអនុញ្ញាតិធ្វើការគូសបញ្ជាក់ អំពីសារៈសំខាន់នៃការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលចំពោះការអនុម័តលើឯកសារស្តីពីជម្រើសនានា ដែលពាក់ព័ន្ធនឹងកំណែទម្រង់ក្នុងការទូទាត់សងដល់បុគ្គលិក មុនពេលរៀបចំវេទិកាសម្រាប់កិច្ចសហការអភិវឌ្ឍន៍កម្ពុជាលើកក្រោយ។ រដ្ឋបាលសាធារណៈ គឺជាកំណែទម្រង់មួយដែលមានការលំបាកក្នុងការអនុវត្ត។ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងគោលបំណងនៃចិរភាពសារពើពន្ធ គឺជាគោលបំណងដែលមានសារៈសំខាន់បំផុតដូចយើងទាំងអស់គ្នាបានពិភាក្សានៅវេលាព្រឹកមិញនេះ។ ជាងនេះទៀត ការឯកភាពគ្នា និងសមធម៌ ក៏ជាតម្រូវការដ៏មានសារៈសំខាន់ ដូចដែលបានកំណត់ដោយរាជរដ្ឋាភិបាល។ យើងខ្ញុំមានការឯកភាពទាំងស្រុងជាមួយរដ្ឋាភិបាលអំពីភាពចាំបាច់ក្នុងការរៀបចំឱ្យមាននូវសកម្មភាពតាមលំដាប់លំដោយច្បាស់លាស់ និងការពិភាក្សាយ៉ាងជិតស្និទ្ធជាមួយក្រសួងស្ថាប័ននានា ដែលជាទីភ្នាក់ងារអនុវត្តដើម្បីរៀបចំការលើកទឹកចិត្តនានាឱ្យបានសមស្រប ក៏ដូចជាយន្តការគណនេយ្យភាពនានាផងដែរ។ ជាមួយគ្នានេះដែរ ការតាមដានត្រួតពិនិត្យឱ្យបានច្បាស់លាស់លើផលប៉ះពាល់នៃការផ្លាស់ប្តូរនានា ពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈ គឺមានសារសំខាន់បំផុតសម្រាប់រាជរដ្ឋាភិបាលក្នុងការធ្វើតេស្តសាកល្បងនូវការផ្លាស់ប្តូរទាំងនេះ។ ការបង្ហាញអំពីផលប្រយោជន៍នៃការផ្លាស់ប្តូរនេះចំពោះបុគ្គលិក និងការលើកកម្ពស់ការផ្តល់សេវា សាធារណៈឱ្យប្រជាពលរដ្ឋទាំងអស់។

ដៃគូអភិវឌ្ឍន៍ទាំងអស់ មានការគាំទ្រចំពោះគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានកំណត់ថា ការរៀបចំឱ្យមានការផ្ដល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់អន្តរកាល មិនមែនជាដំណោះស្រាយដែលអាចធ្វើទៅបានសម្រាប់រយៈពេលយូរអង្វែងក្នុងការលើកកម្ពស់សេវាសាធារណៈប្រកបដោយចីរភាពនោះទេ។ ពាក់ព័ន្ធនឹងចំណុចនេះ យើងខ្ញុំសូមអបអរសាទរ និងគាំទ្រចំពោះការដឹកនាំ របស់រាជរដ្ឋាភិបាលក្នុងការរៀបចំតាក់តែង ការអនុវត្ត និងការធានាឱ្យក្របខ័ណ្ឌតែមួយសម្រាប់ការផ្ដល់ប្រាក់ឧបត្ថម្ភប្រកបដោយសុខដុមនីយកម្មដល់មន្ត្រីរាជការទាំងអស់។ ការងារជាច្រើនត្រូវបានធ្វើឡើងចំពោះកត្តាមួយនៃក្របខ័ណ្ឌនេះ ដែលពាក់ព័ន្ធនឹងចំណាយប្រតិបត្តិការអាទិភាព (Priority Operational Costs-POC)។ ដៃគូអភិវឌ្ឍន៍នានាគាំទ្រ យ៉ាងខ្លាំងចំពោះគោលការណ៍ដែលរាជរដ្ឋាភិបាលបានស្នើឡើងអំពី "ចំណាយប្រតិបត្តិការអាទិភាព POC" ដែលរួមមានៈ ការប្រើប្រាស់បានសម្រាប់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ មន្ត្រីរាជការម្នាក់ទទួលប្រាក់ឧបត្ថម្ភពីមួយប្រភពតែប៉ុណ្ណោះ ការជ្រើសរើសបុគ្គលិកមកបំរើការងារផ្អែកលើលទ្ធផលដែលត្រូវអនុវត្ត និងមានប្រព័ន្ធរាយការណ៍ប្រកបដោយតម្លាភាព ដែលពាក់ព័ន្ធនឹងការ ជ្រើសរើស និងផ្ដល់ប្រាក់ឧបត្ថម្ភដល់បុគ្គលិក ការត្រួតពិនិត្យជាប្រចាំការអនុវត្តការងាររបស់បុគ្គលិក មានការរៀបចំ របាយការណ៍ជាប្រចាំ និងការគ្រប់គ្រងហិរញ្ញវត្ថុ។ យើងខ្ញុំក៏ស្វាគមន៍ និងគាំទ្រ ការដឹកនាំ និងភាពជាម្ចាស់របស់រាជរដ្ឋាភិបាល ចំពោះផែនការណ៏ POC ដែលកំពុងត្រូវបានអនុវត្តក្នុងការគាំទ្រការប្រតិបត្តិ យុទ្ធសាស្ត្រថ្នាក់រដ្ឋមន្ត្រីដើម្បីសម្រេចបាននូវគោលដៅដែលបានកំណត់ក្នុង NSDP។ ដៃគូអភិវឌ្ឍន៍នានាក៏លើកសរសើរផងដែរចំពោះការដែល POCs នឹងត្រូវលើកយកមកពិភាក្សាជាមួយក្រុមការងារបច្ចេកទេសរបស់ដៃគូអភិវឌ្ឍន៍នានា។

យើងខ្ញុំក៏មានការយល់ស្របផងដែរជាមួយនឹងទស្សនៈរាជរដ្ឋាភិបាលដែលចាត់ទុកថា ការផ្ដល់ប្រាក់ឧបត្ថម្ភនេះគឺគ្រាន់តែជាយន្តការជាបណ្ដោះអាសន្នតែប៉ុណ្ណោះ។ ជាមួយគ្នានេះដែរ យើងខ្ញុំក៏មានសេចក្ដីរីករាយចំពោះការប្ដេជ្ញាចិត្តគួរឱ្យកត់សម្គាល់របស់ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលសាធារណៈក្នុងការពិនិត្យមើលឡើងវិញនូវយន្តការ POCមុនពេលរៀបចំវេទិការសម្រាប់កិច្ចសហការអភិវឌ្ឍន៍កម្ពុជាលើកក្រោយ ដើម្បីឱ្យទាំងអស់គ្នាអាចធ្វើការពិនិត្យរួមគ្នា នៅក្នុងវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា ដែលគ្រោងរៀបចំនៅខែធ្នូ ឆ្នាំ២០១១។

ចំពោះភាគីដៃគូអភិវឌ្ឍន៍ យើងខ្ញុំសូមធ្វើការប្ដេជ្ញាចិត្តសារជាថ្មី ដើម្បីគាំទ្ររាជរដ្ឋាភិបាលក្នុងការពង្រឹងការអនុវត្តគោលនយោបាយនេះ ដែលនឹងផ្ដល់លទ្ធភាពមួយដ៏សំខាន់សម្រាប់កិច្ចខិតខំប្រឹងប្រែងនានារបស់រាជរដ្ឋាភិបាលក្នុងការលើកកំពស់រដ្ឋបាលសាធារណៈ។

ជាសេចក្ដីសន្និដ្ឋាន យើងខ្ញុំសូមលើកឡើងនូវចំណុចសំខាន់ៗចំនួនពីរដើម្បីធ្វើការពិភាក្សានាថ្ងៃនេះ :

**ចំណុចទីមួយ** : កំណែទម្រង់រដ្ឋបាលសាធារណៈដូចខ្ញុំបានគូសបញ្ជាក់រួចមកហើយ គឺមានគោលបំណងពង្រឹងការគ្រប់គ្រងបុគ្គលិក ដើម្បីការលើកកំពស់ការបំពេញការងារ និងគណនេយ្យភាពរបស់ស្ថាប័នសាធារណៈនីមួយៗ។ ដូចយើងទាំងអស់គ្នាបានដឹងហើយថា រាជរដ្ឋាភិបាលកម្ពុជាក៏បានធ្វើការយកចិត្តទុកដាក់ទៅលើកិច្ចខិតខំប្រឹងប្រែងក្នុងការ

លើកកំពស់គណនេយ្យភាពផ្នែកហិរញ្ញវត្ថុនៃអង្គភាពថវិកានានា។ ជាងនេះទៀត នឹងមានកិច្ចខិតខំប្រឹងរួមក្នុងការពង្រឹងសិទ្ធិអំណាចដល់អ្នកគ្រប់គ្រងនានា ដោយផ្តល់សិទ្ធិអំណាចផ្នែកថវិកាកាន់តែច្រើនឡើងក៏ដូចជាការពង្រឹងការទទួលខុសត្រូវក្នុងការគ្រប់គ្រងបុគ្គលិក និងការលើកកំពស់គណនេយ្យភាពខាងផ្នែកហិរញ្ញវត្ថុ ក៏ដូចជាគណនេយ្យភាពក្នុងការអនុវត្តការងារ។ ពាក់ព័ន្ធនឹងការងារនេះ រាជរដ្ឋាភិបាលមានវិធីសាស្ត្រយ៉ាងដូចម្តេចក្នុងការធ្វើការជាមួយគ្នាជាពិសេសតាមរយៈ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីសម្រេចបាននូវគោលបំណងនេះ? ហើយតើចំពោះដៃគូអភិវឌ្ឍន៍ទាំងអស់ គួរធ្វើការគាំទ្រយ៉ាងដូចម្តេចចំពោះរាជរដ្ឋាភិបាល ដើម្បីសម្រេចបាននូវគោលបំណងនេះ?

**ចំពោះចំណុចទី២:**យើងខ្ញុំសូមអបអរសាទរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការដាក់អោយអនុវត្តនូវយន្តការ POC ចាប់ពីដើមខែក្រោយនេះ។ យើងខ្ញុំមានការប្តេជ្ញាចិត្តក្នុងការបន្សុីគ្នា និងធ្វើអោយមានសុខដុមនីយកម្មយ៉ាងពេញលេញជាមួយនឹងយន្តការនេះ។ ពាក់ព័ន្ធនឹងចំណុចនេះ តើរាជរដ្ឋាភិបាលមានផែនការសម្រាប់ជំហ៊ានបន្ទាប់យ៉ាងដូចម្តេច ក្នុងការដាក់ឱ្យអនុវត្តនូវយន្តការ POCនេះ ហើយតើដៃគូអភិវឌ្ឍន៍ទាំងអស់ គួរធ្វើការគាំទ្រដល់រាជរដ្ឋាភិបាលឱ្យបានប្រសើរបំផុតយ៉ាងដូចម្តេច?

**ឯកឧត្តម លោកជំទាវ លោក លោកស្រីជាទីគោរពរាប់អាន!**

ខ្ញុំសូមអនុញ្ញាតិបញ្ចប់នូវបទអន្តរាគមន៍របស់ខ្ញុំត្រឹមនេះ ហើយសូមថ្លែងអំណរគុណឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និងឯកឧត្តម **ង៉ោ ហុងលី** អគ្គលេខាធិការនៃ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ចំពោះការប្តេជ្ញាចិត្ត និងកិច្ចខិតខំប្រឹងប្រែងជានិរន្តន៍យ៉ាងសកម្មរបស់ឯកឧត្តមក្នុងការដឹកនាំកម្មវិធីកំណែទម្រង់រដ្ឋបាល ព្រមទាំងចំពោះការប្តេជ្ញាចិត្ត និងកិច្ចខិតខំប្រឹងប្រែងរបស់បណ្តាក្រសួង និងស្ថាប័នសាធារណៈទាំងអស់ ដើម្បីអនុវត្តកម្មវិធីកំណែទម្រង់រដ្ឋបាល ដ៏មានសារសំខាន់នេះប្រកបដោយភាពជោគជ័យ។

ចំពោះដៃគូអភិវឌ្ឍន៍ទាំងអស់ យើងខ្ញុំមានការប្តេជ្ញាចិត្តយ៉ាងមុតមាំ ក្នុងការគាំទ្ររាជរដ្ឋាភិបាលកម្ពុជា ដើម្បីជំរុញអោយការអនុវត្តបានជោគជ័យរួមទាំងការតាមដានត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពនៃកំណែទម្រង់ទាំងនេះ។

**សូមអរគុណ!**